# ការចែករំលែកសេចក្ដីស្រឡាញ់របស់ព្រះ

*ថាអីស មិនដឹងថាត្រូវនិយាយ ឬធ្វើអ្វីទេ ប៉ុន្តែនាងចង់ជួយ ។*

ដោយ ខារ៉ូលីណា ម៉ាលដូណាដូ
( ផ្អែកទៅលើដំណើររឿងពិត )

*ដំណើររឿងនេះបានកើតឡើងនៅប្រទេស បូលីវៀ ។*

នាព្រឹកដែលមានអាកាសធាតុក្ដៅមួយ ។ ថាអីស និងមិត្តរបស់នាង ក្លូឌា បានជជែក និងសើចនៅពេលពួកគេដើរកាត់ទីលានបាល់ទាត់ ។ ពួកគេទើបតែរៀនចប់ថ្នាក់កីឡា ហើយឥឡូវនេះពួកគេចូលរៀនគណិតវិទ្យា ។

ក្មេងតូចៗកំពុងចេញលេង ។ ថាអីស បានមើលពួកគេលេង ។

ពេលនោះនាងបានឃើញក្មេងស្រីតូចម្នាក់អង្គុយតែម្នាក់ឯងនៅលើកាំជណ្ដើរ ។ ពេលចូលទៅជិត ថាអីស ឃើញនាងយំ ។

ថាអីស បានគ្រវីដៃឲ្យ ក្លូឌា មករកក្មេងស្រីតូចនោះ ។

ក្លូឌា ចងចិញ្ចើម និងគ្រវីក្បាលជាសញ្ញាប្រាប់ថា អត់ទេ ។ « យើងយឺតហើយ » ។





មុនពេល ថាអីស អាចនិយាយអ្វីបាន ក្លូឌា ក៏ដើរចេញទៅ ។

ថាអីស សម្លឹងមើលក្មេងស្រីតូចនោះ ។ នាងមានអាយុប្រហែលប្រាំឆ្នាំ ។ នាងអង្គុយយកដៃឱបក្បាលជង្គង់ ឱនមុខចុះ ។

ថាអីស អង្គុយនៅក្បែរនាង ។ ក្មេងស្រីបានងាកចេញបន្តិច ។

« តើមានរឿងអី ? » ថាអីស បានសួរដោយទន់ភ្លន់ ។

ក្មេងស្រីនោះមិនបានឆ្លើយទេ ។ ថាអីស មិនប្រាកដថាត្រូវនិយាយ ឬធ្វើអ្វីនោះទេ ។

នាងបានសួរទៀតថា « តើបងអាចជួយប្អូនបានទេ ? »

ក្មេងស្រីនោះគ្រវីក្បាល ។

« បងឈ្មោះ ថាអីស ។ តើប្អូនឈ្មោះអី ? »

ទីបំផុតក្មេងស្រីរូបនោះបានមើលទៅ ថាអីស ។ « នីកូល » ។

« មិច បាននីកូលយំ ? »

នាងនិយាយទាំងស្រក់ទឹកភ្នែកថា ៖ « គេនាំគ្នាញ៉ោះខ្ញុំ ដោយសារខ្ញុំធាត់ » ។

ថាអីស ជូតទឹកភ្នែកឲ្យ នីកូល ។ « បងសោកស្ដាយណាស់ដែលពួកគេនិយាយដូច្នោះ ។ វាមិនសំខាន់ទេពីអ្វីដែលពួកគេគិតនោះ » ។

« ពួកគេបាននិយាយថា ខ្ញុំមិនស្អាតទេ » ។

« មែនហើយ បងគិតថាពួកគេនិយាយខុសហើយ ! » ថាអីស និយាយដោយស្នាមញញឹម ។ « ប្អូនស្អាតណាស់ ហើយប្អូនក៏ជាមនុស្សសំខាន់ដែរ ។ តើប្អូនដឹងទេ ? »

ថាអីស បានគិតពីបទចម្រៀងដែលនាងចូលចិត្តនៅអង្គការបឋមសិក្សា ។ នាងដឹងពីអ្វីដែលត្រូវនិយាយឥឡូវនេះ ។

ថាអីស និយាយដោយចាប់ដៃក្មេងស្រីនោះថា « ប្អូនគឺជាបុត្ររបស់ព្រះ » ។

ថាអីស បាននិយាយបន្តិចបន្តួចជាមួយ នីកូល ។ នាងបានពន្យល់ នីកូល ថាតើនាងមានសារៈសំខាន់យ៉ាងណាចំពោះព្រះវរបិតាសួគ៌ គ្រួសាររបស់នាង និងមនុស្សជាច្រើនទៀតដែលស្រឡាញ់នាងយ៉ាងខ្លាំង ។ បន្តិចម្ដងៗ នីកូល ចាប់ផ្ដើមញញឹម ។





ប៉ុន្មាននាទីក្រោយមក នីកូល បានក្រោកឈរឱប ថាអីស យ៉ាងណែន ។ នាងបាននិយាយថា « អរគុណ ! » ។

ថាអីស មើលមិត្តថ្មីរបស់នាងរត់ចេញទាំងញញឹមយ៉ាងស្រស់ ។ វាមានអារម្មណ៍ល្អក្នុងការជួយនីកូល ឲ្យមានអារម្មណ៍ប្រសើរឡើង ហើយដឹងថាព្រះស្រឡាញ់នាងខ្លាំងប៉ុនណា ។

ពេលនោះ ថាអីស ក៏ហក់លោតឡើងផងដែរ ។ *ខ្ញុំគួរតែរត់ដូចជា នីកូល ដែរហើយ ឬបើមិនអីចឹងទេ ច្បាស់ជាចូលរៀនគណិតវិទ្យាយឺតដែរហើយ !* នាងរត់ប្រញាប់ចូលថ្នាក់ទាំងញញឹមក្នុងចិត្ត ។